ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការពារជាតិ
អគ្គនាយកដ្ឋានឃោសសេវា
នាយកដ្ឋានព័ត៌មាន
លេខៈ ០៣៩/នទ
/១០១៦

# សេចក្ដីប្រកាសព័ត៌មាន

នាយកដ្ឋានព័ត៌មាន អគ្គនាយកដ្ឋានឃោសសេវា ក្រសួងការពារជាតិ សូមជម្រាបជូនដំណឹងដល់ សាធារណជនឲ្យបានជ្រាបថា គណៈកម្មាធិការព្រំដែនទូទៅ កម្ពុជា-ថៃ (GBC) គ្រោងនឹងបើក សម័យប្រជុំលើកទី ១១ របស់ខ្លួនពីថ្ងៃទី ២១-២៤ ខែមីនា ឆ្នាំ២០១៦ នៅទីក្រុងបាងកក នៃព្រះ រាជាណាចក្រថៃ ។

គណៈប្រតិភូភាគីកម្ពុជា ដឹកនាំដោយ **ឯកឧត្ដម នាយឧត្ដមសេនីយ៍ ទៀ បាញ់** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ នៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងគណៈប្រតិភូភាគីថៃដឹកនាំដោយ **ឯកឧត្ដម នាយឧត្ដមសេនីយ៍ ប្រាវិត វង្សសុវ៉ាន់** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារប្រទេសនៃព្រះរាជាណាចក្រថៃ នឹងអញ្ជើញចូលរួមកិច្ចប្រជុំរយៈពេល៤ថ្ងៃ (ពីថ្ងៃទី២១-២២ ប្រជុំថ្នាក់ក្រុមការងារ និងពីថ្ងៃទី២៣-២៤ ប្រជុំពេញអង្គ) ។

គណៈកម្មាការព្រំដែនទូទៅកម្ពុជាថៃ (GBC) រៀបចំកិច្ចប្រជុំប្ដូរវេនរបស់ខ្លួនមួយឆ្នាំម្ដង ដែលលើកនេះប្រទេសថៃទទួលធ្វើម្ចាស់ផ្ទះដោយផ្ដោតលើគោលការសំខាន់ៗ៣ចំណុចៈការងារសន្តិសុខ, ទំនាក់ទំនងនិងកិច្ចសហប្រតិបត្តិការ, ព្រមទាំងការកសាង និងអភិវឌ្ឍន៍នៅតាមបណ្ដោយព្រំដែនប្រទេសជិតខាងទាំងពីរ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៦

នាយកដ្ឋានព័ត៌មាន